ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...០២.ប្រក.ព...

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍នៃវិបត្តិ, ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងអំឡុង និងក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩
**(ជុំទី១០ , ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ២០២១)**

វិបត្តិនៃជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលមកលើសង្គម-សេដ្ឋកិច្ចទូទៅ ជាមួយនឹងវត្តមានជាបន្តបន្ទាប់នៃមេរោគជំងឺកូវីដ-១៩បំប្លែងថ្មី ដែលបង្កនូវភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់ ដល់សកលលោកទាំងមូល ។ ជាក់ស្តែង ការបន្តអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការចាក់វ៉ាក់សាំងដ៏មានប្រសិទ្ធភាព ជូនប្រជាពលរដ្ឋរបស់ខ្លួន ក៏ដូចជាខិតខំប្រឹងប្រែងពន្លឿនការអភិវឌ្ឍថ្នាំ និងវិធីសាស្ត្រនានាសម្រាប់ព្យាបាលជំងឺកូវីដ-១៩ នៅតាមបណ្តា ប្រទេសជាច្រើន ដូចជា សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក បានធ្វើឱ្យចរន្តសេដ្ឋកិច្ចនៃប្រទេសទាំងនេះបានងើបឡើងវិញបណ្តើរៗគួរឱ្យកត់សម្គាល់ ។ ដូចបណ្តាប្រទេសដទៃទៀត, រាជរដ្ឋាភិបាលកម្ពុជាក្រោមស្មារតីបុរេសកម្ម បានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដែលក្នុងនោះរាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការគន្លឹះ ហើយជាចុងក្រោយនេះបានសម្រេចចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លើកុមារ-យុវជន និងដូសជំរុញ ជូនដល់ក្រុមអាទិភាពនានា សំដៅបង្កើតឱ្យបានភាពស៊ាំសង្គមសេដ្ឋកិច្ចរឹងមាំ ។ ជាមួយគ្នានេះ, តាមរយៈវឌ្ឍនភាពដ៏ល្អប្រសើរនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំង និងការដាក់ចេញនូវវិធានការសុខាភិបាល, វិធានការរដ្ឋបាលមុតស្រួចនានា និងវិធានការច្បាប់ នាពេលកន្លងមក, ស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ បានចាប់ផ្តើមថមថយ ដែលជាបច្ច័យវិជ្ជមានសម្រាប់ការបើកឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងនេះក្តី, ភាពមិនប្រាកដប្រជាដែលបណ្តាលមកពីការបំប្លែងថ្មីនៃមេរោគកូវីដ-១៩ និងការងើបឡើងវិញយឺតជាងការព្យាករណ៍របស់សេដ្ឋកិច្ចពិភពលោក នៅតែជាក្តីកង្វល់ចំពោះកំណើនសេដ្ឋកិច្ចជាតិ បើទោះបីជាសកម្មភាពសង្គម-សេដ្ឋកិច្ច បាន និងកំពុងបើកឡើងវិញជាបណ្តើរៗតាមគន្លងប្រក្រតីភាពថ្មី ក៏ដោយ ។

ក្នុងបរិការណ៍នេះ, ទន្ទឹមនឹងការរៀបចំដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ព្រមទាំងវិធានការនានា ដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងបន្តជំរុញលំនឹងអាជីវកម្ម-ធុរកិច្ចក្នុងវិស័យដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដូចជា វិស័យកាត់ដេរ-វាយនភណ្ឌ, វិស័យអាកាសចរណ៍ និងវិស័យទេសចរណ៍

ជាដើម, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការបន្ថែមសម្រាប់ជុំទី ១០ ក្នុងគោលបំណង៖ **(១).** បន្តកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនៃជំងឺកូវីដ-១៩ មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ក៏ដូចជាការដាក់ចេញ និងអនុវត្តវិធានការទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ ក្នុងបរិបទនៃការបើកឡើងវិញ ជាបណ្តើរៗនូវសកម្មភាពសង្គម-សេដ្ឋកិច្ច តាមគន្លងប្រក្រតីភាពថ្មី និង **(២).** បន្តសុពលភាព នៃវិធានការដែលបានដាក់ចេញនាពេលកន្លងមក ដែលនឹងផុតកំណត់សម្រាប់ការអនុវត្ត ។ វិធានការជុំទី ១០ ដែលត្រូវបានរៀបចំឡើងក្រោមស្មារតីយកចិត្តទុកដាក់ខ្ពស់ ដោយមានការពិគ្រោះយោបល់ ទូលំទូលាយជាមួយវិស័យឯកជន, ដៃគូអភិវឌ្ឍន៍នានា ព្រមទាំងគ្រប់តួអង្គពាក់ព័ន្ធ រួមមាន ដូចខាងក្រោម ៖

*១. វិធានការបន្តជួយវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ, កាបូប និងវិស័យទេសចរណ៍*

បន្ទាប់ពីរោងចក្រ-សហគ្រាស និងអាជីវកម្មក្នុងវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ, កាបូប និងវិស័យទេសចរណ៍ ទទួលបានលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ និង/ឬលិខិតអនុញ្ញាតឱ្យពន្យារការព្យួរកិច្ចសន្យាការងារ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោយពីបានបំពេញតាមលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌនៃការព្យួរកិច្ចសន្យាការងារ រាជរដ្ឋាភិបាលកម្ពុជានឹង៖

- បន្តផ្តល់ប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករ-និយោជិត ០១ នាក់ ដែលបំពេញការងារក្នុងវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ និងកាបូប សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ២០២១ ។ ម្ចាស់រោងចក្រ-សហគ្រាសក្នុងវិស័យនេះត្រូវបន្ថែមចំនួន ៣០ ដុល្លារអាមេរិក សម្រាប់កម្មករ-និយោជិត ០១ នាក់ (ជាសរុបកម្មករ-និយោជិត ០១ នាក់ ទទួលបាន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ) ។
- បន្តផ្តល់ប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករ-និយោជិត ០១ នាក់ ដែលបំពេញការងារក្នុងវិស័យទេសចរណ៍ ដូចជា៖ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍ សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ២០២១ ។ សហគ្រាស និងអាជីវកម្មក្នុងវិស័យទេសចរណ៍ ត្រូវរួមចំណែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមលទ្ធភាពជាក់ស្តែង បន្ថែមលើអ្វីដែលរាជរដ្ឋាភិបាលបានផ្តល់ជូន ។
- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ តុលា ដល់ ខែ ធ្នូ ឆ្នាំ ២០២១ ។ អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និង ប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែ ក្នុងអំឡុងពេលនៃការលើកលែងនេះ ។
- បន្តលើកលែងការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព នៃបេឡាជាតិសន្តិសុខសង្គម ក្នុងអំឡុងពេលព្យួរអាជីវកម្ម ឬផ្អាកដំណើរការអាជីវកម្ម ។

*២. វិធានការបន្តជួយវិស័យអាកាសចរណ៍*

- បន្តលើកលែងការបង់ពន្ធអប្បបរមា (Minimum Tax) សម្រាប់រយៈពេល ០៣ ខែបន្ថែមទៀត ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ២០២១ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា ។

- បន្តផ្តល់ការអនុគ្រោះចំពោះការបង់ប្រាក់ជំពាក់លើកម្រៃអាកាសចរស៊ីវិល ដោយពន្យាររយៈពេល ០៣ ខែបន្ថែមទៀត ចាប់ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ២០២១ ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តនូវសេចក្តីណែនាំនេះ ទៅតាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានជាប្រចាំ នូវស្ថានភាពនៃជំងឺកូវីដ-១៩, លើស្ថានភាពសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងក្របខណ្ឌសកល, តំបន់ និងក្នុងប្រទេស ដើម្បីពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើវិស័យសំខាន់ៗ ក្នុងទិសដៅធ្វើបច្ចុប្បន្នភាព និងត្រៀមដាក់ចេញនូវវិធានការថ្មីៗបន្ថែមចាំបាច់នានា ក្នុងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសធានាបាននូវចីរភាពនៃភាពស៊ាំសង្គម-សេដ្ឋកិច្ច និងការរៀនផ្លាស់ប្តូរឥរិយាបថដើម្បីសម្របខ្លួនតាមគន្លងប្រក្រតីភាពថ្មី ក្រោមក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទជំងឺកូវីដ-១៩ និងផែនការស្តារសេដ្ឋកិច្ចឡើងវិញ ក្នុងអំឡុង និងក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ។